# ៣០ មីនា ១៩៩៧

## ថ្ងៃសោកនាដកម្ម

## THE MARCH 30, 1997 TRAGEDY



រៀបរៀងដោយ

គណបក្ស សម រង្ស៊ី ខែ មីនា ២០០១

# មហាសោកនាដកម្មដោយឈាម និងទឹកភ្នែកមុខរដ្ឋសភា ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧

សោកនាដកម្មដោយអំពើភេរវកម្មបោកគ្រាប់បែកដៃចំនួន៤គ្រាប់ មកលើក្រុមបាតុករអហិង្សានៅមុខមន្ទីររដ្ឋសភា កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ គិតមកដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០១ គឺមានរយៈពេល៤ឆ្នាំកន្លងផុតទៅហើយ ។ ប៉ុន្តែស្នាមឈាម និងសម្រែកឈឺចាប់របស់អ្នកស្លាប់ អ្នករងរបួសក្នុងពេលនោះ ហាក់ដូចជានៅថ្មីៗនៅឡើយ ហើយបានក្លាយទៅជាប្រវត្តិសាស្ត្រដ៏មហាសែនឈឺចាប់មួយដែលអ្នកស្រឡាញ់សេរីភាព យុត្តិធម៌ និងប្រជាធិបតេយ្យ ចងចាំជារៀងរហូត ។ ជាពិសេសនៅពេលណាដែលគេធ្វើដំណើរឆ្លងកាត់មុខមន្ទីររដ្ឋសភានោះ គេនឹកឃើញភ្លាមដល់មេដឹកនាំឃោរឃៅផ្តាច់ការដែលហ៊ានសំលាប់ខ្មែរគ្នាឯងដោយខ្វះសតិសម្បជញ្ញៈ ។

គេនៅចាំថា ព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ លោក សម រង្ស៊ី បានដឹកនាំធ្វើបាតុកម្មអហិង្សាមួយនៅមុខមន្ទីររដ្ឋសភា។ បាតុកម្មនេះមានមនុស្សគ្រប់ស្រទាប់វណ្ណៈជាច្រើនរយនាក់ ចូលរួមដើម្បីទាមទារអោយរដ្ឋាភិបាលកែទំរង់ប្រព័ន្ធតុលាការដ៏មហាពុករលួយ ដែលជាបុព្វហេតុនាំឲ្យមានអំពើអយុត្តិធម៌នៅក្នុងសង្គមជាតិ ។ ប៉ុន្តែការទាមទារយុត្តិធម៌ និងលទ្ធិប្រជាធិបតេយ្យនេះ ពុំមានមេដឹកនាំខ្មែរណាម្នាក់ទទួលយកទៅដោះស្រាយឡើយ ។ ផ្ទុយទៅវិញ គេបានបង្កើតនូវមហាសោកនាដកម្មយ៉ាងព្រៃផ្សៃបំផុត ដោយបានធ្វើឲ្យទីលានមុខមន្ទីររដ្ឋសភាជិតដាមដោយស្នាមឈាម និងទឹកភ្នែកព្រមទាំងសម្រែកឈឺចាប់របស់បាតុករស្លូតត្រង់ ។

វេលាម៉ោង៨និង៣០នាទីព្រឹក ក្នុងពេលដែលស្ត្រីតំណាងជនរងគ្រោះដោយអំពើអយុត្តិធម៌ កំពុងរៀបរាប់ពីទុក្ខសោកដោយសារតុលាការពុករលួយ

ស្រាប់តែស្នូរគ្រាប់បែកចំនួន៤គ្រាប់ បានផ្ទុះយ៉ាងសន្ធាប់ជ្រែកក្រុមបាតុករអហិង្សាដែលកំពុងឈរទាមទារយុត្តិធម៌នៅមុខមន្ទីររដ្ឋសភារាប់រយនាក់ ហើយលេចឮជាសម្រែកគួរឲ្យរន្ធត់ជាទីបំផុត ។ មនុស្សជាច្រើននាក់បានស្លាប់ភ្លាមៗ ដិតដាមដោយឈាមក្រហមឆ្អៅគួរឲ្យសង្វេគក្រៃលែង ឯមនុស្សរាប់រយនាក់ទៀតត្រូវរងរបួស ស្រែកថ្ងូរលាន់គ្រលួច ដង្ហោយរកឲ្យឪពុកម្តាយបងប្អូនកូនចៅ និងញាតិមិត្ត ឲ្យជួយដោយសំលេងតក់ស្លុតគួរឲ្យអាណិតអាសូរហួសវាចានឹងថ្លែង ។

ក្រុមឃាតកស៊ីឈ្នួលអ្នកកាន់អំណាច ដែលជាអ្នកបោកគ្រាប់បែកសំលាប់ក្រុមបាតុករអហិង្សាយ៉ាងព្រៃផ្សៃទាំងនោះ ក្រោយពេលដែលពួកគេបានបោកគ្រាប់បែកសំលាប់ខ្មែរគ្នាឯងរួចហើយ គេបានរត់ចូលទៅកាន់តំបន់ដែលការពារដោយក្រុមអង្គរក្សលោក ហ៊ុន សែន នៅក្រោយវត្តបទុមវតី ដោយសុវត្ថិភាព ។ រហូតមកដល់ពេលនេះ ក្រុមឃាតកស៊ីឈ្នួលទាំងនោះ រួចខ្លួនយ៉ាងរំភើយ គ្មានតុលាការ ឬច្បាប់ឯណាហ៊ានប៉ះពាល់ពួកគេបានឡើយ ដោយសារពួកគេមានមេដឹកនាំចិត្តអឲ្យតិរ្ថិយ ចាំការពារគេពីក្រោយខ្នងយ៉ាងគឃ្លើន ។ ប៉ុន្តែភ្នាក់ងារស៊ើបអង្កេត F B I របស់អាមេរិកបានបង្ហាញភស្តុតាង និងមុខមាត់ក្រុមឃាតកស៊ីឈ្នួលទាំងនោះខ្លះៗរួចមកហើយ ដែលមិនយូរទេ ក្រុមឃាតកស៊ីឈ្នួល និងមេឃាតកដែលជាអ្នកបញ្ជាពីក្រោយខ្នង ប្រាកដជាត្រូវបានFBIវែកមុខជាពុំខាន ។

សោកនាដកម្មថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ គឺជាស្លាកស្នាមប្រវត្តិសាស្ត្រដ៏មហាសែនឈឺចាប់ខ្លោចផ្សាដែលមេដឹកនាំឃោរឃៅផ្តាច់ការបញ្ជាឲ្យឃាតកស៊ីឈ្នួល មកបោកគ្រាប់បែកសំលាប់បាតុករអហិង្សាយ៉ាងកំរោលជាទីបំផុត ដោយបាតុករទាំងនោះគ្មានកំហុសអ្វីបន្តិចទាល់តែសោះ ។ វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ដោយអយុត្តិធម៌លើទីលានប្រជាធិបតេយ្យ នៅមុខមន្ទីររដ្ឋសភា

មិនទាន់បានស្ងប់នៅឡើយទេ ដរាបណាមេដឹកនាំឃោរឃៅផ្ដាច់ការ និងក្រុមឃាតកស៊ីឈ្នួលពុំទាន់ត្រូវបានគេផ្ដន្ទាទោសទៅតាមផ្លូវច្បាប់ ។ វិញ្ញាណក្ខន្ធអ្នកទាំងនោះ កំពុងតែដង្ហោយហៅឲ្យកូនខ្មែរស្នេហាជាតិទាំងអស់ក្រោកឡើងតស៊ូដើម្បីទាមទារយុត្តិធម៌ និងលទ្ធិប្រជាធិបតេយ្យ រហូតទទួលបានជោគជ័យយ៉ាងពិតប្រាកដ ។

សោកនាដកម្មថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ គឺជាសោកនាដកម្មពោរពេញដោយស្នាមឈាម និងទឹកភ្នែក ព្រមទាំងសម្រែកឈឺចាប់ដែលយើងពុំអាចធ្វើការពណ៌នាឲ្យបានសព្វគ្រប់នូវអ្វីដែលយើងបានឃើញនោះឡើយ ព្រោះអីវាជាសោកនាដកម្មដែលមេដឹកនាំសំលាប់ប្រជាពលរដ្ឋខ្លួនឯងយ៉ាងអគតិ ។ ស្នាមឈាម និងទឹកភ្នែករបស់ក្រុមបាតុករអហិង្សាដែលគេផ្ដាច់ជីវិតដោយគ្មានធម៌មេត្តា នៅមុខមន្ទីររដ្ឋសភា បានស្ថិតនៅជាប់ជានិច្ចក្នុងឧត្តមគតិ និងអារម្មណ៍របស់អ្នកស្នេហាយុត្តិធម៌ និងស្នេហាលទ្ធិប្រជាធិបតេយ្យសេរី ហើយគេនឹងយកគំរូវីរភាពដ៏ក្លាហានរបស់អ្នកទាំងនោះមកអនុវត្តដើម្បីទាមទារយុត្តិធម៌ និងលទ្ធិប្រជាធិបតេយ្យរហូតដល់បានសំរេចតាមបំណងប្រាថ្នាជាក់ជាមិនខាន ។

សោកនាដកម្មថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ ត្រូវបានគេចារទុកជាប្រវត្តិសាស្ត្រថាជាថ្ងៃមេដឹកនាំផ្ដាច់ការអាយ៉ងយួនសំលាប់ប្រជាពលរដ្ឋខ្លួនឯងយ៉ាងឃោរឃៅព្រៃផ្សៃជាទីបំផុត តាមរយៈអំពើបោកគ្រាប់បែកសំលាប់បាតុករស្លូតត្រង់នៅមុខមន្ទីររដ្ឋសភា ។ អំពើយង់ឃ្នងរបស់ជនផ្ដាច់ការនេះ បានត្រូវប្រជាពលរដ្ឋខ្មែរដែលស្រឡាញ់សេរីភាព និងយុត្តិធម៌នៅទូទាំងប្រទេសធ្វើការថ្កោលទោសយ៉ាងខ្លាំងក្លាបំផុតដោយមិនអាចអត់អោនឲ្យបានឡើយ ។

សម្លេងថ្ងូចថ្ងូរដោយក្ដីឈឺចាប់ក្នុងអន្លង់សោកនាដកម្មថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ និងស្នាមឈាមដ៏ក្រហមឆ្អិនឆ្អៅរបស់អ្នកស្នេហាយុត្តិធម៌ ស្នេហា

លទ្ធិប្រជាធិបតេយ្យ ដែលបានបូជាជីវិតមុខមន្ទីររដ្ឋសភានាពេលនោះ ជាគំរូវីរភាពដ៏ប្រពៃថ្លៃថ្លាបំផុតសំរាប់កូនខ្មែរជំនាន់ក្រោយ ។

យើងមានមោទនភាពខ្លាំងណាស់ ដោយសារគណបក្ស សម រង្ស៊ី បានសាងសង់ចេតិយ៍នៅលើសួនច្បារមុខមន្ទីររដ្ឋសភា ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធអ្នកស្នេហាយុត្តិធម៌ ស្នេហាលទ្ធិប្រជាធិបតេយ្យ ស្នេហាជាតិទឹកដីដែលបានស្លាប់ដោយសារអំពើឃោរឃៅរបស់មេដឹកនាំផ្តាច់ការដែលគ្មានវិចារណញ្ញាណ ។ ការសាងសង់ចេតិយ៍របស់គណបក្ស សម រង្ស៊ី គឺជាសក្ខីភាពមួយ ដែលបានបញ្ជាក់ថាខ្មែរចេះស្រលាញ់ខ្មែរ និងឲ្យតំលៃជីវិតមនុស្សថ្លៃលើសអ្វីៗទាំងអស់ ។

យើងសូមបួងសួងឲ្យវិញ្ញាណក្ខន្ធអ្នកស្នេហាយុត្តិធម៌ ស្នេហាលទ្ធិប្រជាធិបតេយ្យ និងអ្នកស្នេហាជាតិទឹកដីដែលបានស្លាប់នៅក្នុងមហាសោកនាដកម្មថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ នៅមុខមន្ទីររដ្ឋសភាបានទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ៕

# បញ្ជីរាយនាមអ្នកស្លាប់ក្នុងពេលបាតុកម្ម
# នៅមុខមន្ទីររដ្ឋសភា

១-លោក ជេត ដួងតារាវុធ
២-លោក ហាន មុន្នី
៣-លោក សំ សារិន
៤-កញ្ញា យង់ សុខនៅ
៥-កញ្ញា យង់ ស្រី
៦-លោកស្រី យស់ សៀម
៧-កុមារី ចន្ទី ភក្តី
៨-កុមារា រស់ សឿ
៩-កញ្ញា សុខ ខេង
១០-លោក យឿន យន
១១-លោក ជា ណាង
១២-លោក ណម ធី

<u>**កំណត់សំគាល់**</u> :

មានអ្នកបាត់បង់ជីវិតចំនួនប្រមាណ៧នាក់ទៀត ដែលគេមិនស្គាល់ឈ្មោះ ហើយត្រូវបានឃើញដោយអ្នកសារពត៌មាន និងអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ បន្ទាប់ពីមានការបោះគ្រាប់បែកទៅលើហ្វូងបាតុករ និងអ្នកដែលកំពុងឈរ ឬធ្វើដំណើរជិតខាង ។



## ជេត ផ្លុងតារាវុធ

ជេត ផ្លុងតារាវុធ ភេទប្រុស អាយុ២៩ឆ្នាំ

-កើតនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៦៨ នៅទីក្រុងភ្នំពេញ

-ជាវេជ្ជបណ្ឌិត ដែលបានបញ្ចប់ការសិក្សា នៅមហាវិទ្យាល័យវេជ្ជសាស្ត្រ ក្នុងឆ្នាំ១៩៩៣ (ជំនាន់ទី១៤) នៅទីក្រុងភ្នំពេញ ។

-ជាសមាជិកគណៈកម្មាធិការនាយកនៃគណបក្សជាតិខ្មែរ (គ.ជ.ខ) និងជាអ្នកកាសែតប្រឆាំង ដែលមានឈ្មោះថា “អ្នកប្រយុទ្ធ” ។

-បានរៀបការជាមួយនាង ប៊ុត វ៉ារុន មានកូនចំនួន២នាក់ ។

-ទទួលមរណភាព នៅមុខមន្ទីររដ្ឋសភា ។



## ហាន មុន្នី

ហាន មុន្នី ភេទប្រុស អាយុ ៣២ឆ្នាំ

-កើតនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៦៥ នៅភូមិកំពង់ចំលង ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

-កំរិតវប្បធម៌ : មធ្យមសិក្សាបឋមភូមិ

-ជាសន្តិសុខនៃគណបក្សជាតិខ្មែរ (មុនចូលបំរើ គ.ជ.ខ ជាទាហាន នៅក្នុងកងយោធពលខេមរភូមិន្ទ) ។

-បានរៀបការ មានកូនចំនួន១នាក់ ។

-ទទួលមរណភាពនៅមុខមន្ទីររដ្ឋសភា ក្នុងខណៈពេលដែលគាត់ការពារ លោក សម រង្ស៊ី ។



## សំ សារិន

សំ សារិន ភេទប្រុស អាយុ ៥០ឆ្នាំ

-កើតនៅឆ្នាំ១៩៤៧ នៅភូមិដីឥដ្ឋ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល

-ជានាយទាហាន និងជាសកម្មជន ត.ជ.ខ

-កំរិតវប្បធម៌ : មធ្យមសិក្សាបឋមភូមិ

-បានរៀបការ មានកូនចំនួន៥នាក់ ។

-ទទួលមរណភាពនៅមន្ទីរពេទ្យ ព្រះនរោត្តមសីហនុ(អតីតពេទ្យរុស្ស៊ី) ។



## យង់ សុខនៅ

យង់ សុខនៅ ភេទស្រី អាយុ២០ឆ្នាំ

-កើតនៅឆ្នាំ១៩៧៤ នៅភូមិបុរីកម្មករ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល ។

-កំរិតវប្បធម៌ : ថ្នាក់ទី៦ ថ្មី

-ជាកម្មកររោងចក្រកាត់ដេរ ជិនណាន់ នៅទីក្រុងភ្នំពេញ ។

-បានចូលរួមធ្វើបាតុកម្ម ជាមួយកម្មកររោងចក្រកាត់ដេរលើកដំបូងបង្អស់ ដែលដឹកនាំដោយលោក សម រង្ស៊ី ។

-ទទួលមរណភាព នៅមន្ទីរពេទ្យកាល់ម៉ែត ។



# យង់ស្រី

យង់ ស្រី ភេទស្រី អាយុ ២១ឆ្នាំ

-កើតនៅថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៧៦ នៅភូមិព្រៃមាស ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្ដាល ។

-កំរិតវប្បធម៌ ៖ ថ្នាក់ទី៥ ចាស់

-ជាកម្មកររោងចក្រកាត់ដេរ ជីនណាន់ នៅទីក្រុងភ្នំពេញ ។

-បានចូលរួមធ្វើបាតុកម្ម ជាមួយកម្មកររោងចក្រកាត់ដេរលើកដំបូងបង្អស់ ដែលដឹកនាំដោយលោក សម រង្ស៊ី ។

-ទទួលមរណភាព នៅមន្ទីរពេទ្យ ព្រះនរោត្តមសីហនុ (អតីតពេទ្យរុស្ស៊ី) ។



# យស់ សៀម

យស់ សៀម ភេទស្រី អាយុ៣៦ឆ្នាំ

-កើតនៅឆ្នាំ១៩៦១ នៅភូមិកណ្ដាលជើម ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

-កំរិតវប្បធម៌ : ថ្នាក់ទី៣ ថ្មី

-ជាកម្មកររោងចក្រកាត់ដេរ ជីនណាន់ នៅទីក្រុងភ្នំពេញ ។

-ជាស្ត្រីមេម៉ាយ មានកូន៣នាក់ ។

-បានចូលរួមធ្វើបាតុកម្ម ជាមួយកម្មកររោងចក្រកាត់ដេរលើកដំបូងបង្អស់ ដែលដឹកនាំដោយលោក សម រង្ស៊ី ។

-ទទួលមរណភាព នៅមន្ទីរពេទ្យ កាល់ម៉ែត ។



## ចន្ទី ភក្តី

ចន្ទី ភក្តី ភេទស្រី អាយុ១៣ឆ្នាំ ជាសិស្សនៃអនុវិទ្យាល័យ បឹងកេងកង ។

-កើតនៅឆ្នាំ១៩៨៤ នៅភូមិពែងមាសជើង ឃុំស្តី ស្រុកចំការលើ ខេត្ត កំពង់ចាម ។

-បានចូលរួមធ្វើបាតុកម្ម ដើម្បីតវ៉ាប្រឆាំងនឹងអំពើអយុត្តិធម៌ ។

-ទទួលមរណភាព នៅមន្ទីរពេទ្យ កាល់ម៉ែត ។



## រស់ សៀ

រស់ សៀ ភេទប្រុស អាយុ ១៣ឆ្នាំ

-កើតនៅឆ្នាំ១៩៨៤ នៅភូមិទួលព្រះវិហារ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

-ជាក្មេងកំព្រា ហើយបានរស់នៅជាមួយបងប្រុស ដែលជាព្រះសង្ឃនៅវត្តមហាមន្ត្រី ។

-កំរិតវប្បធម៌ : ថ្នាក់ទី៥ ថ្មី

-បានចូលរួមធ្វើបាតុកម្មប្រឆាំងនឹងអំពើអយុត្តិធម៌ ។

-ទទួលមរណភាព នៅមន្ទីរពេទ្យ ព្រះកុសុមៈ (អតីតពេទ្យលោកសង្ឃ)។



## សុខ ខេង

សុខ ខេង ភេទស្រី អាយុ ១៨ឆ្នាំ

-កើតនៅឆ្នាំ១៩៧៩ នៅភូមិ ពែងមាសជើង ឃុំស្ដី ស្រុកចំការលើ ខេត្តកំពង់ចាម ។

-កំរិតវប្បធម៌ : ថ្នាក់ទី៧ ថ្មី

-បានចូលរួមធ្វើបាតុកម្ម ដើម្បីតវ៉ាប្រឆាំងនឹងអំពើអយុត្តិធម៌ ។

-ទទួលមរណភាព នៅមន្ទីរពេទ្យកាល់ម៉ែត ។



## ជា ណាង ហៅ ឆាង គួង

ជា ណាង ភេទប្រុស អាយុ២៨ឆ្នាំ ជាគ្រូបង្រៀននៅអនុវិទ្យាល័យវត្តភ្នំ ។

-កើតនៅឆ្នាំ១៩៦៩ នៅទីក្រុងភ្នំពេញ

-កំរិតវប្បធម៌ : មធ្យមសិក្សាកំរិត២

-អ្នកបើកបរឡានដឹកទឹកសុទ្ធ "ឆ្វេងកាត់មុខរដ្ឋសភា" ។

-បានរៀបការ មានកូនចំនួន១នាក់ ។

-ទទួលមរណភាព នៅមន្ទីរពេទ្យក្នុងប្រទេសវៀតណាម ។



## យឿន យន

យឿន យន ភេទប្រុស អាយុ១៧ឆ្នាំ ជាសិស្សអនុវិទ្យាល័យ ព្រះយុគន្ធរ ។

-កើតនៅឆ្នាំ១៩៨០ នៅភូមិចំបក់ ឃុំពុតស ស្រុកបាទី ខេត្តតាកែវ ។

- កំរិតវប្បធម៌ : ថ្នាក់ទី ៨ ថ្មី

-រស់នៅវត្តមហាមន្ត្រី

-បានចូលរួមធ្វើបាតុកម្ម ដើម្បីតវ៉ាប្រឆាំងនឹងអំពើអយុត្តិធម៌ ។

-ទទួលមរណភាពនៅមន្ទីរពេទ្យ ព្រះនរោត្តមសីហនុ(អតីតពេទ្យរុស្ស៊ី)។



## ណាម ធី

ណាម ធី ភេទប្រុស អាយុ៣៧ឆ្នាំ

-កើតនៅឆ្នាំ១៩៦០ នៅភូមិព្រៃកតាកេ ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្ដាល ។

-កំរិតវប្បធម៌ ៖ ថ្នាក់ទី៤ ចាស់

-ជាអ្នករត់ម៉ូតូឌុប និងជាសកម្មជនគណបក្សជាតិខ្មែរ ។

-បានរៀបការ មានកូនចំនួន ៥នាក់ ។

-ទទួលមរណភាពនៅមន្ទីរពេទ្យ ព្រះកុសុមៈ (អតីតពេទ្យលោកសង្ឃ)។









